ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ...ធ៨.១៣.....០២៤..០២០..ប្រកាសព័ត៌មាន

*ថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# សិក្ខាសាលាផ្សព្វផ្សាយ "របាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០២៣"

នៅថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ "របាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០២៣" នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ ក្រោមអធិបតីភាព លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា។

ចាប់តាំងពីឆ្នាំ២០១៩មក ធនាគារជាតិនៃកម្ពុជាបានផ្សព្វផ្សាយរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុកម្ពុជា ក្នុងគោលបំណងផ្តល់ការវិភាគ វាយតម្លៃ និងបង្ហាញពីទស្សនអនាគតលើស្ថានភាពស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។ នៅឆ្នាំ២០២៣កន្លងទៅ ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាបន្តមានស្ថិរភាពល្អនិងភាពធន់ ទោះប្រឈមនឹងសម្ពាធពីកត្តាខាងក្រៅមួយចំនួន ដូចជា ការកើនឡើងនៃភាពតានតឹងនិងការបែងចែកផ្នែកភូមិសាស្ត្រនយោបាយ កម្រិតខ្ពស់នៃអត្រាការប្រាក់ និងអតិផរណាសកល។ ទ្រព្យសកម្ម និងប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារបានបន្តកើនឡើងក្នុងអត្រា ៨,២% និង ១៣% រៀងគ្នា។ ជាមួយគ្នានេះ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអភិវឌ្ឍនិងធ្វើទំនើបកម្មជាបន្តបន្ទាប់ ស្របពេលដែលវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមមាន ទីផ្សារហិរញ្ញវត្ថុ និងវិស័យធានារ៉ាប់រងក៏បានបន្តរីកចម្រើនជាលំដាប់ផងដែរ។

ស្ថិរភាពហិរញ្ញវត្ថុក៏ទទួលបានភាពអំណោយផល ពីការបន្តងើបឡើងនៃកំណើនសេដ្ឋកិច្ចនៅឆ្នាំ២០២៣ ជាមួយនឹងកម្រិតទាបនៃអត្រាអតិផរណា និងស្ថិរភាពអត្រាប្តូរប្រាក់។ ទុនបម្រុងអន្តរជាតិវិញ បានកើនឡើងដល់ ២០ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់បាន ៧ខែ ខ្ពស់ជាងកម្រិតអប្បបរមាដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន (៣ខែ)។

ទោះយ៉ាងណា ការងើបឡើងនៃវិស័យចម្បងមានល្បឿនខុសគ្នា ដូចជាវិស័យអចលនទ្រព្យបានថយចុះ វិស័យសំណង់មានកំណើនទាប ចំណែកឯវិស័យផ្សេងទៀតមិនទាន់ងើបឡើងវិញទាំងស្រុងដូចគ្រាមុនវិបត្តិកូវីដ-១៩នៅឡើយ។ ស្ថានភាពនេះ គួបផ្សំនឹងការបង្កើនការប្រុងប្រយ័ត្នក្នុងការផ្តល់ឥណទានខ្ពស់ជាងមុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បាននាំឱ្យកំណើនឥណទានថយចុះមកត្រឹម ៤,២%។ កំណើនយឺតនៃឥណទាន គួបផ្សំនឹងការបញ្ចប់វិធានការអនុគ្រោះចំពោះការរៀបចំឥណទានឡើងវិញក្នុងអំឡុងវិបត្តិកូវីដ-១៩ បាននាំឱ្យអនុបាតឥណទានមិនដំណើរការកើនឡើងលឿន ប៉ុន្តែអាចគ្រប់គ្រងបាន។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ចំពោះទស្សនវិស័យសម្រាប់ឆ្នាំ២០២៤ ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាត្រូវបានរំពឹងថានឹងបន្តមានស្ថិរភាពរឹងមាំ និងរួមចំណែកគាំទ្រសេដ្ឋកិច្ចកម្ពុជា។ ហានិភ័យចម្បងៗ ជាពិសេសពីកត្តាខាងក្រៅបន្តមាន ដូចជា ការអូសបន្លាយនៃភាពតានតឹង និងការបែងចែកផ្នែកភូមិសាស្ត្រនយោបាយ ភាពមិនប្រាកដប្រជាក្នុងទីផ្សារអចលនទ្រព្យនៅប្រទេសចិន ការប្រែប្រួលអាកាសធាតុ និងការកើនឡើងនៃហានិភ័យសាយប័រ។

ប្រឈមនឹងហានិភ័យទាំងនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានយ៉ាងយកចិត្តទុកដាក់ និងវាយតម្លៃជាប្រចាំទៅលើភាពរឹងមាំនៃគ្រឹះស្ថាន ក៏ដូចជាប្រព័ន្ធធនាគារទាំងមូល។ យ៉ាងណាមិញ ស្ថិរភាពហិរញ្ញវត្ថុគឺជាការងារអន្តរវិស័យ ដែលទាមទារឱ្យមានកិច្ចសហការ និងសម្របសម្រួលពីអាជ្ញាធរ និងភាគីពាក់ព័ន្ធទាំងវិស័យសាធារណៈនិងឯកជន ដើម្បីធានានូវស្ថិរភាពនិងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាទាំងមូល។

របាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុនេះត្រូវបានបោះពុម្ព និងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា ដែលសាធារណជនអាចទាញយកបានចាប់ពីពេលនេះតទៅ។

**ទំនាក់ទំនង ៖**

អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦

អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**

www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA